# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យគោរពព្រះកាយនិងព្រះលោហិតនៅព្រះសហគមន៍សន្តីម៉ារីញញឹម
# ចំការទៀង ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០
## នៅក្នុងអង្គព្រះគ្រីស្តយើងជារូបកាយតែមួយ

**អត្ថបទទី១៖ ទុតិយកថា ៨,២-៣,១៤ខ-១៦ក**

ចូរនឹកចាំថាព្រះអម្ចាស់ ជាព្រះរបស់អ្នក បានឲ្យអ្នកធ្វើដំណើរកាត់វាលរហោស្ថាននេះ អស់រយៈពេលសែសិបឆ្នាំ ដើម្បីឲ្យអ្នកស្គាល់ទុក្ខលំបាក។ ទក ៨,២

**អត្ថបទទី២៖ កូរិនថូស ទី១ ១០,១៦-១៧**

មាននំប៉័ងតែមួយប៉ុណ្ណោះ ទោះបីយើងមានគ្នាច្រើនក្តី ក៏យើងរួមគ្នាមកជារូបកាយតែមួយដែរ ព្រោះយើងទាំងអស់គ្នាបានទទួលចំណែកពីនំប៉័ងតែមួយ។ ១ករ ១០,១៧

**ដំណឹងល្អ៖ យ៉ូហាន ៦,៥១-៥៨**

អាហារដែលបានចុះពីស្ថានបរមសុខមក មានប្រសិទ្ធភាពខុសពីអាហារដែលបុព្វបុរស*របស់អ្នករាល់គ្នាបានបរិភោគ។ យហ ៦,៥៨ក

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងគោរពលើកតម្កើងព្រះកាយនិងព្រះលោហិតរបស់ព្រះគ្រីស្ត យើងបានស្តាប់អត្ថបទដែលណែនាំឲ្យយើងត្រូវតែគិតពិចារណា អំពីអត្ថន័យនិងតម្លៃនៃជីវិតរបស់យើង។ យើងបានស្តាប់ថា "**ខ្ញុំនេះហើយជាអាហារដែលមានជីវិតចុះមកពីស្ថានបរមសុខ អ្នកណាដែលបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច**" នៅក្នុងអត្ថបទទីពីរយើងបានស្តាប់ថា "**ដោយសារនំប៉័ងតែមួយ យើងដែលមានគ្នាច្រើនក៏រួមគ្នាជារូបកាយតែមួយដែរ ព្រោះយើងទាំងអស់គ្នាទទួលចំណែកពីនំប៉័ងតែមួយនោះ**"។ ប្រសិនបើយើងគិតមួយភ្លែតៗ យើងយល់ថាម្ហូបអាហារសម្រាប់មនុស្សយើងសំខាន់ណាស់ បើគ្មានម្ហូបអាហារយើងរស់នៅមិនបាន ម្ហូបអាហារជាថាមពល ជាកម្លាំង ដើម្បីឲ្យយើងពីមួយថ្ងៃទៅមួយថ្ងៃយើងអាចមានសកម្មភាព ឬនៅរស់តែម្តង។ ក្នុងមួយថ្ងៃមនុស្សប្រុសត្រូវការមាន២២០០កាឡូរី មនុស្សស្រីត្រូវការមាន១៥០០កាឡូរី តាមពិតនៅក្នុង១៥០០ឬ២២០០កាឡូរី ដែលយើងត្រូវការមានជាថាមពល នៅក្នុងនេះមាន១៥០០កាឡូរីដើម្បីឲ្យបេះដូងយើងមានចលនា ដើម្បីឲ្យសួតរបស់យើងមានដង្ហើម ដើម្បីឲ្យខួរក្បាលរបស់យើងដើរ។ មានន័យថា រូបកាយរបស់យើងទោះបីយើងមិនធ្វើអ្វីសោះ ក៏យើងត្រូវការ១៥០០កាឡូរី ដើម្បីឲ្យយើងមានជីវិត។ អ្នកធ្វើការក្នុងការិយាល័យយើងប្រើថាមពលតិច អ្នកដែលយើងជាកម្មករ ឬកសិករយើងប្រើថាមពលច្រើន។

ប៉ុន្តែ ថ្ងៃនេះព្រះយេស៊ូនិយាយអំពីម្ហូបអាហារផ្សេង នៅពេលព្រះយេស៊ូបាននិយាយអំពីម្ហូបអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច នៅពេលព្រះយេស៊ូបានឲ្យនំនិងត្រីចិញ្ចឹមជីវិតរបស់គេសិន។ ព្រះយេស៊ូបានគិតអំពីសេចក្តីត្រូវការរបស់ប្រជាជន ដែលកំពុងអង្គុយស្តាប់ព្រះអង្គពីរបីថ្ងៃកន្លងមក ព្រះយេស៊ូដឹងថាគេឃ្លានដូច្នេះព្រះអង្គបានឲ្យនំប៉ុងនិងត្រីទៅគេបរិភោគ។ នៅពេលគេញ៉ាំឆ្អែតអស់ហើយ គេប្រមូលត្រីនិងនំប៉ុងសល់១២ល្អីទៀត ក្រោយមកព្រះយេស៊ូចូលនៅក្នុងដំណាក់កាលមួយទៀត ដោយបង្ហាញថាមនុស្សយើងមិនរស់ដោយសារនំប៉ុងនិងត្រីតែប៉ុណ្ណឹង ប៉ុន្តែមនុស្សយើងនៅរស់ដោយសារម្ហូបអាហារ ដែលផ្តល់ជីវិតអស់កល្បជានិច្ចចុះពីស្ថានបរមសុខមក។ ហេតុនេះហើយ នៅក្នុងអត្ថបទនេះណែនាំឲ្យយើងចាប់ផ្តើមយល់អំពីជីវិតរបស់យើងមិនមែនតែរស់នៅលើផែនដីនេះ ជីវិតរបស់យើងគឺជាជីវិតអស់កល្បជានិច្ចជាមួយព្រះយេស៊ូ។ ដូច្នេះ តម្លៃនៃជីវិតទៅជាតម្លៃថ្មីមែនទែន យើងមិនគិតអំពីជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ យើងដឹងថាព្រះយេស៊ូណែនាំឲ្យយើងទទួលជីវិតអស់កល្បជានិច្ច។ សេចក្តីស្លាប់នៅលើផែនដីនេះត្រូវតែមក ក៏ប៉ុន្តែយើងដឹងថាព្រះយេស៊ូយាងមកដើម្បីឲ្យជីវិតរបស់យើងមានអត្ថន័យដ៏ពេញលក្ខណៈ និងរកឃើញជីវិតអស់កល្បជានិច្ចនៅស្ថានបរមសុខ។

នៅក្នុងអត្ថបទទីពីរ ព្រះយេស៊ូមានព្រះបន្ទូលថា "**យើងទាំងអស់គ្នាទោះបីយើងគ្នាច្រើនក៏ដោយ យើងរួមគ្នាជារូបកាយតែមួយ**" ដោយសារយើងទាំងអស់គ្នាទទួលព្រះកាយព្រះគ្រីស្ត។ សព្វថ្ងៃ យើងរស់នៅក្នុងពិភពថ្មីដែលយើងគិតថា យើងអាចបង្កើតទំនាក់ទំនងបានច្រើនណាស់តាមរយៈមធ្យោបាយថ្មីដែលគេបានបង្កើត។ យើងបានឃើញ ជំងឺកូវីដ១៩ពេលមាននៅប្រទេសណាមួយ វាបានចម្លងដល់ប្រទេសផ្សេងៗ ទាំងបញ្ហាជំងឺកូវីដ១៩ ទាំងបញ្ហាសេដ្ឋកិច្ច ដោយសារយើងទីពឹងលើគ្នាទៅវិញទៅមក។ យើងអាចនិយាយថា ពិភពលោកជាភូមិតែមួយ ដែលយើងមានទំនាក់ទំនងរវាងគ្នានិងគ្នា ទាំងរកស៊ី ទាំងសេដ្ឋកិច្ច ទាំងនយោបាយ ទាំងទំនាក់ទំនងការបរទេស ទាំងមនុស្សនិងមនុស្ស ដែលគេហៅថា សកលភាវូបនីយកម្ម។ នេះជាពាក្យថ្មីដែលគេទើបតែបង្កើតប៉ុន្មានឆ្នាំមុន ប៉ុន្តែព្រះយេស៊ូបានបង្កើតពាក្យនេះ២០០០ឆ្នាំមុន ដោយសារព្រះកាយព្រះគ្រីស្តព្រះយេស៊ូបានណែនាំ ឲ្យមនុស្សទាំងអស់នៅក្នុងពិភពលោកទាំងមូលទៅជារូបកាយតែមួយ។

នៅទីក្រុង ពេលយើងអត់មានអគ្គិសនី (ភ្លើង) យើងចាប់ផ្តើមរអ៊ូរទាំខ្លាំងណាស់ នៅជនបទយើងមានអគ្គិសនីថ្មីៗ ពេលដាច់ភ្លើងមួយភ្លែតយើងចាប់ផ្តើមរអ៊ូរទាំដែរ។ ប៉ុន្តែ ពីមុនយើងឥតមានបញ្ហានេះទេ យើងមានអាគុយ យើងមានចង្កៀង យើងមានព្រះចន្ទ…។ ដោយសារ ជំងឺកូវីដ១៩ប្រសិនបើយើងមានបញ្ហាណាមួយ ដែលចូលនៅក្នុងអ៊ិនធើណេតពិភពលោក ចូលនៅក្នុង

អគ្គិសនីពិភពលោក ចូលនៅក្នុងសេដ្ឋកិច្ចនៃពិភពលោក មួយភ្លែតយើងចូលនៅក្នុងភាពងងឹតអស់ហើយយើងមិនដឹងធ្វើអ្វី។ ប៉ុន្តែ បើយើងគិតអំពីព្រះយេស៊ូព្រះអង្គលើកផុតពីបញ្ហាទាំងនោះ ព្រះយេស៊ូចង់ឲ្យយើងមានជីវិតអស់កល្បជានិច្ច ព្រះយេស៊ូណែនាំឲ្យយើងទៅជារូបកាយតែមួយនៅក្នុងអង្គព្រះគ្រីស្ទ។ ដូច្នេះ មានសេវាឬឥតមានសេវា មានអ៊ិនធើណេតឬគ្មានអ៊ិនធើណេត មានអគ្គិសនីឬគ្មានអគ្គិសនី ឥតមានបញ្ហាទេព្រោះថានៅក្នុងអង្គព្រះគ្រីស្ទយើងជារូបកាយតែមួយ។ នេះជាការអស្ចារ្យដែលយើងទទួលថ្ងៃនេះ ដើម្បីយល់ថានៅក្នុងអង្គព្រះគ្រីស្ទយើងជាគ្រួសារតែមួយនៅលើផែនដី រួមជាមួយបងប្អូនទាំងអស់ដែលនៅស្ថានបរមសុខ។

ម្សិលមិញ ម្តាយរបស់លោកអភិបាល គីគេ បានទទួលមរណភាពក្នុងអាយុ៩៦ឆ្នាំ ប៉ុន្មានឆ្នាំចុងក្រោយគាត់ខ្សោយទៅៗប៉ុន្តែពោរពេញដោយស្មារតី។ ការទទួលមរណភាពរបស់គាត់ប្រៀបដូចជាមនុស្សចូលដេកដែលមិនភ្ញាក់ ដោយដឹងថាឥលូវនេះគាត់នៅស្ថានបរមសុខ ដែលជាគ្រួសារតែមួយធំណាស់ទាំងនៅលើផែនដី ទាំងនៅស្ថានបរមសុខ យើងធ្វើដំណើរជាមួយគ្នានៅក្នុងសេចក្តីសង្ឃឹមនៃជីវិតអស់កល្បជានិច្ច។ នេះសំខាន់ណាស់សម្រាប់យើងជាគ្រីស្តបរិស័ទដើម្បីយល់ថាទោះបីជីវិតរបស់យើងខ្សោយក៏ដោយ ទោះបីពិភពលោកយើងខ្សោយក៏ដោយ យើងមានទីពឹងមួយដែលណែនាំឲ្យយើងមានកម្លាំងថែមទៀត គឺព្រះយេស៊ូផ្ទាល់។

មានរឿងមួយដែលឪពុកណែនាំឲ្យកូនគាត់ទៅលេងនៅជនបទ កូននេះមិនដែលចេញពីទីក្រុងទេ ដូច្នេះឪពុកចង់ឲ្យមើលជីវិតរបស់អ្នកស្រុកស្រែ គេបានស្នាក់នៅមួយថ្ងៃនៅស្រុក។ ពេលគេត្រលប់មកវិញ ឪពុកសួរកូនថា **តើបានទទួលបទពិសោធអ្វីខ្លះ**? កូនបានឆ្លើយថា នៅផ្ទះយើងមានតែឆ្កែមួយ ប៉ុន្តែនៅជនបទផ្ទះនីមួយៗគេមានគ្រប់សត្វ (មានឆ្កែ មានមាន់ មានទា មានគោ មានឆ្មា...)។ នៅផ្ទះយើងមានអាងហែលទឹកមួយ ប៉ុន្តែនៅជនបទមានបឹង មានស្ទឹង មានទន្លេ..។ នៅផ្ទះយើងមានភ្លើងអំពូលដើម្បីបំភ្លឺពេលយប់ ប៉ុន្តែនៅជនបទអត់មានអំពូលទេមានតែផ្កាយ មានតែព្រះចន្ទ ដែលបំភ្លឺពេលយប់។ ម៉ាក់ពេលត្រូវការម្ហូបគាត់ទៅផ្សារទិញ ប៉ុន្តែនៅជនបទគេមានស្រាប់ មានពងមាន់ មានពងទា មានមាន់ មានទា មានបន្លែ...។ ផ្ទះយើងមានរបង មានជញ្ជាំងដើម្បីការពារសុវត្ថិភាព ប៉ុន្តែនៅជនបទគេការពារគ្នាទៅវិញទៅមក សួរសុខទុក្ខគ្នានៅក្នុងអំណរសប្បាយ។ នៅផ្ទះយើងពេលអផ្សុកយើងមើលទូរទស្សន៍ និងគ្មានទំនាក់ទំនងជាមួយអ្នកណាសោះ នៅជនបទគេអត់មានទូរទស្សន៍ ប៉ុន្តែពេលគេអផ្សុកគេទៅលេងពីផ្ទះមួយទៅផ្ទះមួយសប្បាយណាស់។ ដូច្នេះ សូមបងប្អូនប្រុងប្រយ័ត្នកុំឲ្យជីវិតស្រុកស្រែរបស់យើងឆ្លងពីជីវិតទីក្រុង ប៉ុន្តែសព្វថ្ងៃយើងចាប់ផ្តើមឆ្លងបន្តិចម្តងៗហើយ។

នេះជាបញ្ហាមួយ កូវីដ១៩បានណែនាំឲ្យយើងភ្ញាក់ដែរអ្វីដែលសំខាន់សម្រាប់ជីវិតរបស់យើង។ ប្រសិនបើយើងបាត់បង់មិត្តសម្លាញ់ ប្រសិនបើយើងបាត់បង់ឯកទេសទំនើបៗ ដែលណែនាំឲ្យជីវិតរបស់យើងរស់នៅស្រួល ប្រសិនបើយើងគ្មានម្ហូបអាហារលក់នៅលើទីផ្សារ ប្រសិនបើយើងគ្មានលុយ យើងធ្វើដូចម្ដេច? ព្រះយេស៊ូមិនបានណែនាំឲ្យយើងមានលុយឬគ្មានលុយ ប៉ុន្ដែព្រះអង្គបានណែនាំឲ្យយើងមានព្រះបន្ទូលដែលផ្ដល់កម្លាំង កម្លាំងហ្នឹងណែនាំឲ្យយើងតស៊ូទៅមុខបាន។ ប្រសិនបើ យើងទីពឹងលើទ្រព្យសម្បត្តិទាំងស្រុងជីវិតរបស់យើងទៅជាជីវិតលោភលន់ ទៅជាជីវិតច្រណែន ទៅជាជីវិតអាត្មានិយម។ យើងយល់ថាអ្វីដែលសំខាន់ គឺគ្រួសារយើង ការសិក្សា ព្រះជាម្ចាស់ បង្កើតទំនាក់ទំនងពិតៗជាមួយបងប្អូនឯទៀតៗ។ ពិតមែន យើងត្រូវការលុយ យើងត្រូវការម្ហូប ប៉ុន្ដែមិនមែនទៅជាអាទិភាព ពេលយើងបូជាឬកប់ **តើយើងបូជាទ្រព្យសម្បត្តិរបស់យើងជាមួយ?** ផ្ទុយទៅវិញ ណែនាំឲ្យអ្នកនៅរស់ឈ្លោះដណ្ដើមទ្រព្យសម្បត្តិគ្នា។ អ្វីដែលសំខាន់ គឺទំនាក់ទំនងដែលយើងបានបង្កើតនៅក្នុងអង្គព្រះគ្រីស្ដ ណែនាំឲ្យយើងរកឃើញសេចក្ដីសុខ ដោយដឹងថាយើងអាចទីពឹងលើព្រះជាម្ចាស់។

ថ្ងៃនេះ ខ្ញុំសុំព្រះជាម្ចាស់ប្រទានពរលើពូជបន្លែ លើពូជស្រូវ ដែលជាពូជនៃជីវិត យើងអង្វរព្រះជាម្ចាស់កុំឲ្យយើងខ្វះម្ហូបអាហារ កុំឲ្យយើងខ្វះថាមពលដើម្បីរស់នៅ។ ប៉ុន្ដែ កុំឲ្យយើងភ្លេចគ្រួសារយើង ទំនាក់ទំនងដែលយើងមានរវាងគ្នានិងគ្នា ព្រះជាម្ចាស់ ការសិក្សា មិត្តសម្លាញ់របស់យើង ជាអាទិភាពដើម្បីទៅមុខ ដើម្បីរកឃើញសេចក្ដីសង្ឃឹមយ៉ាងពិតប្រាកដ។ កុំភ្លេចលះបង់ចោល ពេលយើងលើកទឹកចិត្តគេ ពេលយើងជួយគេ យើងបានទទួលរង្វាន់ធំនៅស្ថានបរមសុខ។ ព្រះមហាក្សត្រចេញពីវាំងទៅដល់ភូមិមួយ ដែលមានគ្រួសារក្រីក្រមួយសប្បាយចិត្តណាស់ដោយសង្ឃឹមថាថ្ងៃនេះព្រះមហាក្សត្រយាងមក ខ្ញុំនឹងបានទទួលអំណោយយ៉ាងច្រើន។ ពេលព្រះមហាក្សត្រយាងមកដល់ ព្រះអង្គបានចុះមកសុំអង្ករពីអ្នកក្រីក្រនោះ ណែនាំឲ្យគាត់គិតនិងមិនសប្បាយចិត្ត។ ក្រោយមក គាត់បើកថង់អង្កររបស់គាត់ហើយថ្វាយព្រះមហាក្សត្របីគ្រាប់ ពេលគាត់ទៅផ្ទះវិញជាមួយប្រពន្ធគាត់បានបើកថង់អង្ករគាត់ ឃើញមានអង្ករមាសបីគ្រាប់។ នេះណែនាំឲ្យគាត់ភ្ញាក់ស្មារតី ប្រសិនបើគាត់បានថ្វាយអង្ករព្រះមហាក្សត្រទាំងអស់ យប់នេះគាត់មានមាសមួយថង់។ យើងឲ្យតិចយើងទទួលបានតិច។ អាម៉ែន៕